SOUTHERN CALIFORNIA EDISON®

Energy for What's Ahead℠

# ទទួលបានជំនួយហិរញ្ញវត្ថុ ដែលអ្នកត្រូវការ



## បន្តទំនាក់ទំនងជាមួយអ្នក។

ទោះបីជាវិធានការឆ្លើយតបបន្ទាន់ជាបណ្តោះអាសន្នទាក់ទងនឹង COVID-19 បានបញ្ចប់ក៏ដោយ ការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជននឹងមិនផ្លាស់ប្តូរឡើយ។ យើងនឹងនៅទីនេះ ដើម្បីជួយអ្នកស្វែងរកកម្មវិធីជំនួយដ៏ត្រឹមត្រូវសម្រាប់គ្រួសាររបស់អ្នក ដើម្បីបន្តជួយអ្នកក្នុងរយៈពេលវែង។

## ស្វែងរកកម្មវិធីដែលប្រសើរ បំផុតសម្រាប់អ្នក

**កាត់បន្ថយវិក្កយបត្ររបស់អ្នក ដោយអាស្រ័យលើប្រាក់ចំណូលរបស់អ្នក**
អ្នកអាចនឹងមានសិទ្ធិទទួលបានជំនួយក្នុងការបង់វិក្កយបត្រ ថាមពលរបស់អ្នកដោយអាស្រ័យលើ ប្រាក់ចំណូលគ្រួសាររបស់អ្នក។

**ទូទាត់សមតុល្យរបស់អ្នកជាបន្តបន្ទាប់**
អ្នកអាចនឹងមានសិទ្ធិទទួលបានគម្រោងសងប្រាក់វិញ ក្នុងរយៈពេល 12 ខែ ដើម្បីផ្តល់ពេលវេលាបន្ថែមដល់អ្នក ក្នុងការទូទាត់វិក្កយបត្រថាមពលរបស់អ្នក ឬសម្រាប់ការលើកលែងបំណុល តាមរយៈគម្រោងគ្រប់គ្រងបំណុលនៅជំពាក់ (AMP) របស់យើង។

**ទាញយកអត្ថប្រយោជន៍ពីការបញ្ចុះតម្លៃ**
ទទួលបានការបញ្ចុះតម្លៃអគ្គិសនីសម្រាប់ឧបករណ៍វេជ្ជសាស្ត្រ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬសន្សំសំចៃលើឧបករណ៍ប្រើប្រាស់ថាមពលនានា ដែលមានប្រសិទ្ធភាព។

**ទទួលបានជំនួយទូទាត់ប្រាក់មួយដង**
អតិថិជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចទទួលបានជំនួយរូបិយវត្ថុមួយដងជាមួយនឹងវិក្កយបត្រ ថាមពលរបស់ពួកគេ។

## វាមិនទាន់យឺតពេល ក្នុងការទទួលបានជំនួយទេ

យើងមិនអាចទាយទុកជាមុនបានទេ ថានឹងមានអ្វីកើតឡើងនៅថ្ងៃស្អែក។ ប៉ុន្តែសូមធានាថា ទោះជាមានអ្វីកើតឡើងក៏ដោយ, SCE គឺនៅជាមួយ អ្នកជានិច្ច។ ពីការគ្រប់គ្រងការប្រើប្រាស់ថាមពលរបស់អ្នករហូតដល់ជួយក្នុងការទូទាត់វិក្កយបត្ររបស់អ្នក, យើងបានផ្តល់ឲ្យអ្នកនូវការធានារ៉ាប់រង។

## ការពារខ្លួនអ្នកពីជនបោកប្រាស់

ដោយសារតែជនបោកប្រាស់បន្តផ្តោតលើអតិថិជនប្រើប្រាស់អគ្គិសនី, យើងចង់ធានាថាអ្នកមានធនធាន និងយល់ដឹង អំពីអ្វីដែលត្រូវធ្វើដើម្បីឲ្យមានសុវត្ថិភាព។

ស្វែងយល់ពីរបៀបការពារខ្លួនអ្នក តាមរយៈគេហទំព័រ **sce.com/scamalert**។

## ដាក់ពាក្យសុំជំនួយនៅថ្ងៃនេះ

ស្វែងរកជម្រើសនានា និងរកជម្រើសមួយដែលប្រសើរបំផុតសំរាប់ ស្ថានភាពរបស់អ្នក ។ ដាក់ពាក្យសុំឥឡូវនេះ តាមរយៈគេហទំព័រ **sce.com/findsupport** ឬហៅទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខ 1-800-655-4555។